00912058

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 05 / 2013
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E236/5/3/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង** — **សាធារណៈ / Public**

ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣

**ផ្ញើជូន៖** គ្រប់ភាគីទាំងអស់, សំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រមទាំងអស់ និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង; អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU); ការិយាល័យមេធាវីការពារក្តី

**កម្មវត្ថុ៖** ការបង្គាប់របស់អង្គជំនុំជម្រះឱ្យមានការរៀបចំផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-13

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ពេលវេលាឱ្យចំនួន ០៤ ថ្ងៃ ដើម្បីបង្ហាញទឡ្ហីករណ៍ស្តីពីការឈឺចាប់ក្នុងអំឡុងពេលសវនាការស្តីពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មមកលើជនរងគ្រោះ (ឯកសារ E236/5)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យដើមបណ្តឹងរដ្ឋប្បវេណីមួយរូបផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង (ឯកសារ E236/5/3/1.1)។ គោលបំណងនៃសវនាការស្តីពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មមកលើជនរងគ្រោះ គឺដើម្បីផ្តល់ឱកាសឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបង្ហាញភស្តុតាងដែលពាក់ព័ន្ធនឹងសំណងសមូហភាព និងផ្លូវចិត្ត (វិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង) ហើយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗមានពេលកំណត់ចំនួន ៧៥ នាទីសម្រាប់ផ្តល់សក្ខីកម្ម។ វាជាឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះក្នុងការសម្រេចថា គួរ ឬមិនគួរឱ្យមានសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ នៅក្នុងករណីនេះ អង្គជំនុំជម្រះយល់ឃើញថា ពុំចាំបាច់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើដំណើរពីប្រទេសបារាំង មកប្រទេសកម្ពុជាដើម្បីផ្តល់សក្ខីកម្មទាក់ទងនឹង

ចម្លើយរបស់គាត់ស្តីពីការឈឺចាប់ទេ ដោយអង្គជំនុំជម្រះយល់ឃើញថា គាត់អាចផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍បាន។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឲ្យមានការរៀបចំផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-13 ពីប្រទេសបារាំងបាន។ អង្គជំនុំជម្រះបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) រៀបចំរាល់មធ្យោបាយទាំងអស់ដែលចាំបាច់ រួមជាមួយនឹងអាជ្ញាធរពាក់ព័ន្ធផង ដើម្បីរៀបចំការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣។